PTI0058

# សម្ភាសន៍ជាមួយឈ្មោះ គង់ ឈឿន ភេទប្រុស អាយុ៥៩ឆ្នាំ

# មុខងារជំនាន់ខ្មែរក្រហម«យោធា»

ស្រុកកំណើតនៅភូមិសង្គ្រាម ឃុំសង្គ្រាម ស្រុកស្ទោង ខេត្តកំពង់ធំ

រស់នៅភូមិថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២០ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០ៈ៣៥ៈ៣៤

២១ទំព័រ

វណ្ណៈៈ ចឹងខ្ញុំឈ្មោះសុខ វណ្ណៈ ។

ឈឿនៈ បាទ ។

វណ្ណៈៈ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាហើយខ្ញុំមកជួបអ្នកស្រុកអ្នកភូមិចង់ដឹងរឿងរ៉ាវជាប្រវត្តិសាស្ត្រដែលអ៊ំធ្លាប់កាត់មក ។

ឈឿនៈ បាទ ។

វណ្ណៈៈ ហើយចង់បានរឿងរ៉ាវទាំងអស់ហ្នឹងចងក្រងជាសៀវភៅទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពុណាអ៊ំណាស់ ។

ឈឿនៈ បាទ ។

វណ្ណៈៈ ចឹងបទសម្ភាសន៍ខ្ញុំជាមួយអ៊ំតើអ៊ំអនុញ្ញាតឲ្យពួកខ្ញុំយើងទៅចងក្រងជាសៀវភៅបានទេ?

ឈឿនៈ បាទ!យកទៅចុះអត់មានបញ្ហាអីទេ ។

វណ្ណៈៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២០ខែ៥ឆ្នាំ២០១១ ។

ឈឿនៈ បាទ ។

វណ្ណៈៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះអីដែរ?

ឈឿនៈ ខ្ញុំឈ្មោះគង់ ឈឿន ។

វណ្ណៈៈ អ៊ំអាយុប៉ុន្មានហើយ?

ឈឿនៈ អ៊ំកើតឆ្នាំ១៩៥២ ។

វណ្ណៈៈ ចឹងកើតឆ្នាំ១៩៥២ណឹស?

ឈឿនៈ បាទ ។

វណ្ណៈ ចឹងប្រពន្ធអ៊ំឈ្មោះអីដែរ?

ឈៀវៈ ប្រពន្ធខ្ញុំឈ្មោះ អ៊ុច រីម ។

វណ្ណៈ គាត់អាយុប៉ុន្មានហើយ?

ឈៀវៈ គាត់អាយុប្អូនខ្ញុំ៤ឆ្នាំ ។

វណ្ណៈ ប្រហែលជាប៉ុន្មាន?

ឈៀវៈ ខ្ញុំចូល៦០គាត់ប្រហែលជា៥៦អី ។

វណ្ណៈ ចឹង៥៦ឆ្នាំអី?

ឈៀវៈ បាទ ។

វណ្ណៈ សព្វថ្ងៃមានកូនចៅប៉ុន្មាន?

ឈៀវៈ សព្វថ្ងៃកូនចៅមានតែមួយគត់ ។

វណ្ណៈ អ!មានតែម្នាក់?

ឈៀវៈ បាទ ។

វណ្ណៈ ហើយនៅម្នាក់ហ្នឹងរៀបការហើយឬមួយនៅលីវ?

ឈៀវៈ រៀបការហើយគេទៅនៅស្រុកឥឡូវនៅតែពីរនាក់យាយតាហ្នឹង ។

វណ្ណៈ អ!នៅតែពីរនាក់យាយតាខ្វះកូនដែរ?

ឈៀវៈ បាទ ។

វណ្ណៈ ចឹងឪពុកអ៊ំឈ្មោះអីដែរ?

ឈៀវៈ ឪពុកខ្ញុំឈ្មោះគង់ ញ៉ែម ។

វណ្ណៈ ម្ដាយ?

ឈៀវៈ ម្ដាយឈ្មោះ កើត ពុំ ។

វណ្ណៈ ចឹងសព្វថ្ងៃអ្នកទាំងពីរហ្នឹងគាត់នៅរស់ដែរ?

ឈៀវៈ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ ស្លាប់ជំនាន់ណា?

ឈៀវៈ ស្លាប់ជំនាន់យើងឥឡូវៗនេះដែរ ។

វណ្ណៈ ចឹងស្លាប់ក្រោយ៧៩?

ឈៀវៈ បាទ!ក្រោយ៧៩ទាំឆ្នាំ៨២ គាត់ស្លាប់នៅឆ្នាំ៨២ ។

វណ្ណៈ ចឹងបងប្អូនបង្កើតមានប៉ុន្មាននាក់?
ឈឿវៈ បងប្អូនបង្កើតមានបីនាក់ ។
វណ្ណៈ សព្វថ្ងៃនៅទាំងអស់គ្នា?
ឈឿវៈ បាទ!នៅទាំងអស់គ្នា ។
វណ្ណៈ ស្រុកកំណើតពូកើតនៅភូមិអី?
ឈឿវៈ កើតនៅភូមិសង្រ្កាម ឃុំសង្រ្កាម ស្រុកស្ទោង ។
វណ្ណៈ ភូមិសង្រ្កាម?
ឈឿវៈ បាទ ។
វណ្ណៈ ភូមិសង្រ្កាម ឃុំសង្រ្កាមតាំងពីដើមមកឈ្មោះចឹងតែម្តង?
ឈឿវៈ បាទៗ!តាំងពីដើមជីដូនជីតាមកម្ល៉េះ ។
វណ្ណៈ ស្រុកស្ទោង?
ឈឿវៈ បាទ ។
វណ្ណៈ ខេត្តកំពង់ធំ?
ឈឿវៈ ខេត្តកំពង់ធំ តែរាល់ថ្ងៃគេប្រែទៅស្រុកប្រាសាទបាល័ង្ករាល់ថ្ងៃ ។
វណ្ណៈ បាទ ។
ឈឿវៈ តែយើងនិយាយពីដើមអតីតមកណាស់ ។
វណ្ណៈ បាទ!ឥឡូវស្រុកប្រាសាទបាល័ង្កវិញ?
ឈឿវៈ បាទ!នៅបាល័ង្ក ។
វណ្ណៈ ចឹងបច្ចុប្បន្នពូនៅភូមិអី?
ឈឿវៈ នៅស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ។
វណ្ណៈ ចឹងសព្វថ្ងៃអ៊ីប្រកបមុខរបរអីអ៊ឹ?
ឈឿវៈ ធ្វើចំការស្រែចឹងហើយ ។
វណ្ណៈ ស្រុកវាលវែង ខេត្តពោធិសាត់?
ឈឿវៈ បាទ ។
វណ្ណៈ ចឹងសព្វថ្ងៃធ្វើចំការ?
ឈឿវៈ បាទ!ឈប់ពីទាហានអស់ហើយ ឈប់ដោយខ្លួនឯងឈប់ដោយស្ម័យប្រវត្តិវាឆ្អែតហើយ ។

វណ្ណៈ ចឹងកាលពីតូចអ៊ំរៀនបានត្រឹមថ្នាក់អីដែរ?

ឈៀវៈ អ៊ំរៀនបានត្រឹមថ្នាក់ទី១០ ។

វណ្ណៈ ទី១០ចាស់?

ឈៀវៈ បាទ!ទី១០ចាស់ ស្មើថ្នាក់ទី៣យើងតាមមើល ស្មើទី២ទី៣ ។

វណ្ណៈ កាលហ្នឹងរៀននៅសាលាណា សាលាវត្តឬសាលាអី?

ឈៀវៈ សាលាវត្តក៏រៀន សាលាយើងក៏រៀនដែរ ។

វណ្ណៈ បាទ!តែសាលាដែលអ៊ំរៀនហ្នឹង អ៊ំមានចាំឈ្មោះសាលាហ្នឹងទេ?

ឈៀវៈ សាលាភូមិសង្ក្រាម ឃុំសង្ក្រាមហ្នឹងឯង ។

វណ្ណៈ ចឹងសាលាបឋមសិក្សាសង្ក្រាម?

ឈៀវៈ បាទ!សាលាបឋមសិក្សាសង្ក្រាមហ្នឹងឯង ។

វណ្ណៈ អ៊ំបានរៀនដល់ឆ្នាំណាហើយអ៊ំឈប់ទៅធ្វើអី អ៊ំរៀបរាប់មើលថាមូលហេតុអីបានអ៊ំឈប់អី ចឹង ?

ឈៀវៈ មើលអ៊ំឈប់ប្រហែលជាឆ្នាំ៦៨-៦៩ហ្នឹងឯង ប្រហែលជាប៉ុណ្ណឹងឯងដល់ឆ្នាំ៧០ទៅអ៊ំដឹងគ្គី អីចឹងទៅក៏វាមានចូលរំដោះចូលអីអ៊ំចូលនិងគេទៅ ។

វណ្ណៈ បាទ ។

ឈៀវៈ គេហៅថាខ្មែររំដោះពីដើមនោះ ។

វណ្ណៈ កាលហ្នឹងអ៊ំឮមានពីណាឃោសនាឬមានពីណាជាអ្នកនាំចូល?

ឈៀវៈ គេឃោសនាហ្នឹងហើយ គេថាខ្មែររំដោះយើងត្រូវតែប្រយុទ្ធប្រឆាំងពួកសក្តិភូមិនាយទន់ប្រតិ កិរិយាអីហ្នឹងណាស់ ពីដើមមកហ្នឹង ។

វណ្ណៈ បាទ ។

ឈៀវៈ ក៏ទៅគេឯងហ្នឹងទៅ ។

វណ្ណៈ ចឹងកន្លែងភូមិចូលហ្នឹងដឹងថាគ្នាច្រើនទេភូមិពូហ្នឹង?

ឈៀវៈ ច្រើនអូនច្រើន ។

វណ្ណៈ ចូលដំបូងហ្នឹងពូចូលនៅកន្លែងណាតំបន់ភូមិអី?

ឈៀវៈ នៅភូមិរបស់អ៊ំហ្នឹងឯង ។

វណ្ណៈ បាទ ។

ឈៀវៈ នៅភូមិសង្ក្រាម ឃុំសង្ក្រាម ។

វណ្ណៈ ឆ្នាំណាដែលអ៊ីចូលទៅ?

ឈៀវៈ អ៊ីចូលនៅឆ្នាំ៧១ ។

វណ្ណៈ ឆ្នាំ៧១ក្រោយរដ្ឋប្រហាមួយឆ្នាំ?

ឈៀវៈ បាទ ។

វណ្ណៈ ចូលបដិវត្តហ្នឹងកាលហ្នឹងអ៊ីចូលទៅកាន់កាំភ្លើងភ្លាមតែម្តង?

ឈៀវៈ មិនទាន់បានកាន់ទេ មិនទាន់បានកាន់អីទាំងអស់ ។

វណ្ណៈ ចូលទៅដំបូងយ៉ាងម៉េចទៅចឹង?

ឈៀវៈ ចូលទៅគេគ្រាន់តែយកយើងទៅអប់រំរៀនសូត្រអីចឹងទៅ បំពាក់បំប៉នអីហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ឈៀវៈ តែប៉ុណ្ណឹងឯង ។

វណ្ណៈ ចឹងកាលឆ្នាំ៧១ហ្នឹងមានទម្លាក់គ្រាប់បែកអីទេ?

ឈៀវៈ មានទម្លាក់គ្រាប់បែកដល់ចឹងទៅមានមន្ទីរសម្ងាត់ហ្នឹង មន្ទីរនៅក្នុងព្រៃណាស់ ។

វណ្ណៈ បាទ ។

ឈៀវៈ គេហៅមន្ទីរសម្ងាត់ៗហ្នឹងគឺរបស់ពួករំដោះដូចថាយើងថាខ្មែរក្រហមចូលវៀតស៊ូម៉ាគីចឹងណាស់ ។

វណ្ណៈ នៅមន្ទីរសម្ងាត់ហ្នឹងពីណាជាអ្នកគ្រប់គ្រង?

ឈៀវៈ គេនិយាយពីរឿងអង្គការតែអ្នកគ្រប់គ្រងនោះយើងមិនដឹងឈ្មោះអីដែលពីដើមមក ពីដើមមានឈ្មោះ តាំង ពីសោភឹមមាននៅហ្នឹងដែរ ។

វណ្ណៈ បាទ ។

ឈៀវៈ គាត់មាននៅហ្នឹងតែគេខ្ពស់ៗជាងយើង យើងមិនអាចយើងចេះអក្សរបន្តិចបន្តួចយើងអានទៅមាននៅក្នុងនោះ ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងគេនិយាយតែអង្គការទេដឹងនាន់ហ្នឹង?

ឈៀវៈ បាទ!អង្គការៗថ្នាក់លើយើងមិនដែលស្គាល់មុខអង្គការយើងមិនដែលស្គាល់អង្គការថាម៉េចទេ ថ្នាក់លើមិនដឹងជាយ៉ាងម៉េចទេណាស់ ។

វណ្ណៈ បាទ!ចឹងអ៊ីចូលបានប្រហែលជាប៉ុន្មានឆ្នាំ បានអ៊ីកាន់កាំភ្លើងបាញ់ជាមួយទាហានលន់ នល់?

ឈៀវៈ ចូលមកប្រហែលជាពីរឆ្នាំទៅបីឆ្នាំបានកាន់កាំភ្លើងយើងក៏មិនសូវមានកាំភ្លើងណាកាន់ដែរ ពីដើមមានកាសេៗអាគាវ៉ាង អាមូសស្តុងយើងពីដើមហ្នឹង ។

វណ្ណៈ បាទ ។

ឈៀវៈ វាសល់សេសពីជំនាន់បារាំងណាស់ ។

វណ្ណៈ បាទ!អាមម៉េមួយបាញ់មួយ?

ឈៀវៈ បាទ!ហ្នឹងហើយ ។

វណ្ណៈ ដល់ក្រោយមកពុថាមានចិនជំនួយដែលឬមួយយ៉ាងម៉េច?

ឈៀវៈ កាលហ្នឹងមិនទាន់មានទេ ។

វណ្ណៈ បាទ ។

ឈៀវៈ ដល់មកក្រោយមកដល់ឆ្នាំ៧៣-៧៤ហ្នឹងបានចាប់ផ្តើមមានបណ្តើរៗហើយ ។

វណ្ណៈ មានរបស់ល្អៗប្រើ?

ឈៀវៈ មានហើយតែមិនទាន់គ្រប់គ្រាន់ដល់ឆ្នាំ៧៥ទៅបានមានរបស់ប្រើគ្រប់គ្រាន់ ។

វណ្ណៈ អ៊ឹកាលឆ្នាំ៧៤អ៊ឹកាន់កាំភ្លើងហ្នឹងអ៊ឹកាន់នៅមុខព្រួយកំពង់ធំដដែរ?

ឈៀវៈ អត់ទេ អ៊ឹមកកាន់កាលវ៉ៃនេះពោធិសាត់បាត់ដំបងមកនេះវិញ ។

វណ្ណៈ អត់ទាន់បែក៧៥កំពង់តែវ៉ៃជាមួយលន់ នល់នៅឡើយ?

ឈៀវៈ បាទ!វ៉ៃជាមួយលន់ នល់មកខាងពោធិសាត់នេះវិញ ។

វណ្ណៈ ចឹងនៅពេលខ្មែរក្រហមមានកំលាំងលើសលុបវ៉ៃជាមួយទាហានលន់ នល់ឈ្នះនៅឆ្នាំ៧៥អ៊ឹ?

ឈៀវៈ បាទ ។

វណ្ណៈ អ៊ឹបានចូលទៅដល់ណា?

ឈៀវៈ ៧៥ឈ្នះដល់ពេលយើងចាប់ផ្តើមវ៉ៃជាយួនអ៊ឹនៅច្រមុះជ្រូកគេបញ្ជូនឲ្យទៅនោះវិញ ។

វណ្ណៈ ឥឡូវខ្ញុំចង់និយាយថា ឥឡូវយើងឈ្នះនៅឆ្នាំ៧៥ហើយណាស់ ពេលហ្នឹងគេជម្លៀសប្រជាជនពីទីក្រុងភ្នំពេញអីហ្នឹងណាស់ ឆ្នាំ៧៥ ៧៦និង៧៧អ៊ឹអើ?

ឈៀវៈ គេហៅមកប្រជុំនៅកំពង់ឆ្នាំង ។

វណ្ណៈ ចឹងអ៊ឹមកកំពង់ឆ្នាំង?

ឈៀវៈ បាទ ។

វណ្ណៈ អ៊ឹមកធ្វើអីហ្នឹងនៅកំពង់ឆ្នាំង?

ឈឿវៈ គេធ្វើកន្លែងប្រជុំកន្លែងអីហ្នឹងគេរៀបតាមកង១ ចូលជាតាមកងក្រុមអីចឹងទៅណាស់ ។

វណ្ណៈ មិនមែនកន្លែងព្រលានយន្តហោះទេ?

ឈឿវៈ បាទ ។

វណ្ណៈ កំពង់ឆ្នាំងមានព្រលានយន្តហោះ?

ឈឿវៈ ព្រលានយន្តហោះគេទើបធ្វើក្រោយទេ ។

វណ្ណៈ ចឹងនៅពេលចប់ភ្ជាមហ្នឹងគេប្រមូលកំលាំងមកកំពង់ឆ្នាំងហ្នឹងដែរ?

ឈឿវៈ បាទ!មកកំពង់ឆ្នាំងហ្នឹងគេបំបែកជាកងជាក្រុមជាពួកអីចឹងទៅណាស់ ។

វណ្ណៈ ចឹងកងពលអ៊ឹខាងពោធិសាត់ហ្នឹង កាលហ្នឹងពីណាជាអ្នកដឹកនាំកំលាំងវៃចូលទៅក្រុងអីចឹង?

ឈឿវៈ កាលវៃចូលហ្នឹងមិនដឹងជាកងពលធំណាមួយអីមួយឲ្យជាក់ច្បាស់ទេ ពីដើម ។

វណ្ណៈ ចឹងអ៊ឹនៅកងពលប៉ុន្មាន?

ឈឿវៈ កងពល៨០០ប៉ុន្មានទេ ខ្ញុំនៅកងពលលេខ១ តា ញឹមណាស់ តា ញឹមយើងពីដើម ។

វណ្ណៈ រស់ ញឹម?

ឈឿវៈ បាទ ។

វណ្ណៈ ចឹង?

ឈឿវៈ បាទ ។

វណ្ណៈ កាលហ្នឹងរស់ ញឹមនៅបាត់ដំបងតើ?

ឈឿវៈ បាទ!ហ្នឹងហើយចូលមកកងពលហ្នឹងគេបញ្ជូនទៅកំពង់ឆ្នាំងហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ឈឿវៈ ដល់ចឹងបែកបាក់អីទៅក្រោយមកក៏គេកាប់សម្លាប់លិចកើតទៅក៏យើងភាសគេចចេញ ។

វណ្ណៈ ចឹងអ៊ឹនៅខាងពាយ័ព្យណែស?

ឈឿវៈ បាទ!ភូមិភាគពាយ័ព្យ ។

វណ្ណៈ អ៊ឹកាលចូលនៅកំពង់ធំទេ យ៉ាងម៉េចបានជាធាក់ទងមកដល់ពោធិសាត់?

ឈឿវៈ អាហ្នឹងស្រេចតែគេបញ្ជូនយើងមក ។

វណ្ណៈ ចឹងគេបញ្ជូន?

ឈឿវៈ បាទ ។

វណ្ណៈ កាលហ្នឹងនៅខាងកំពង់ធំដូចជាកែវ ពកអីទេ ដែលគាត់គ្រប់គ្រង?

ឈឿវៈ បាទ!កែវ ពកនៅកំពង់ធំមុន ដល់ក្រោយមកឲ្យនៅជាមួយតា ញឹម ពីដើមកែវ ពកម៉ាកំពង់ធំវាខ្លាំងដូចថាវាខ្លាំងជាពាយ័ព្យហើយ ចេះឲ្យទាហានវាជ្រែតជ្រែកមកកង់ទ័ពមកចូលចំរុះមកពីខាងនេះទៅដល់មកមិនដឹងជាយ៉ាងម៉េចទេ យើងក៏មិនសូវដឹងដែរ ដល់ពេលមកចុងក្រោយឡើងយើងដេញចង់នាប់ចង់រស់រត់ទៅវិញ ។

វណ្ណៈ បាទ ។

ឈឿវៈ គេថាពួកយើងខាងនោះសុទ្ធជាអ្នកកាប់សម្លាប់ណាស់ ។

វណ្ណៈ បាទ ។

ឈឿវៈ នៅនោះវាល្អដូចតែគ្នាហ្នឹង អ្នកកាប់សម្លាប់មានអ្នកផ្សេង?

វណ្ណៈ បាទ ។

ឈឿវៈ តែយើងធ្វើតាមបញ្ជារបស់គេដែរ ។

វណ្ណៈ ចឹងម៉ាវៃឈ្នះ៧៥ហ្នឹងអ៊ំមានឋានៈអីដែរ?

ឈឿវៈ អត់មានឋានៈទេ អ៊ំជាកូនទាហានគេ ពីព្រោះយើងអត់មានចេះអក្សរចេះអីផងយើងចេះបន្តិចបន្តួច ។

វណ្ណៈ បាទ ។

ឈឿវៈ មានគេអ្នកចេះច្រើនជាងយើងគេអាចឡើងទៅនេះទៅនោះអីទៅ ។

វណ្ណៈ បាទ ។

ឈឿវៈ អ៊ំជាទាហានតាំងពីតូចរហូតដល់ហើយ ។

វណ្ណៈ ចឹងដល់ពេលអ៊ំមកជាមួយតា ញឹមហ្នឹងមកការពារខាងណា?

ឈឿវៈ មុនគេឲ្យដឹកជញ្ជូនខាងឡានអីមុនណាស់ ។

វណ្ណៈ ៧៦អីហ្នឹង?

ឈឿវៈ បាទ!៧៦ ។

វណ្ណៈ ដឹកជញ្ជូនឡានដឹកអីគេ?

ឈឿវៈ ឡានដឹកអង្ករស្រូវអីចឹងទៅ ។

វណ្ណៈ ដឹកយកទៅខាងណា?

ឈឿវៈ យកមិនដឹងជាយកទៅខាងណាទេ ជួនកាលយកទៅចាក់ចោលក៏មានដែរ ព្រោះយើងជាក់ស្តែងពីដើមមកណាស់ ។

វណ្ណៈ    ចឹងអ៊ឹជាអ្នកដឹកអង្ករយកទៅចាក់ចោល?

ឈៀវៈ  ឡានគេអ្នកដឹកហ្នឹងយើងគ្រាន់ជាអ្នកការពារឡានទេ ។

វណ្ណៈ    បាទ ។

ឈៀវៈ  ចឹងបានជាប្រជាជនយើងអត់បាយអត់អីចឹង  អត់អីស៊ីតាំងពីណើងមក ។

វណ្ណៈ    ចឹងអង្ករដឹកយកទៅចាក់ចោលអត់ឲ្យប្រជាជនហូបទេ?

ឈៀវៈ  បាទ!មិនដឹងជាយ៉ាងម៉េច ។

វណ្ណៈ    ចឹងរឿងហ្នឹងពិតអ៊ឹ?

ឈៀវៈ  បាទ ។

វណ្ណៈ    ឆ្នាំណាអ៊ឹឆ្នាំណា?

ឈៀវៈ  ឆ្នាំ៧៧-៧៨ជិត៧៩ហ្នឹងហើយ  ខោអាវយើងគ្មានស្លៀកសោះហ្នឹង ។

វណ្ណៈ    បាទ ។

ឈៀវៈ  ចាក់ទឹកអាស៊ីតពេញៗអស់  មានតែទាហានគ្រាន់បើបន្តិច ។

វណ្ណៈ    បាទ ។

ឈៀវៈ  ព្រោះពីដើមមកយើងខ្វាចងាប់ណាស់អូនអើយ ។

វណ្ណៈ    បាទ ។

ឈៀវៈ  ខ្វាចណាស់មិនថាអ្នកទាហានអីគឺមិនទាហានអីខ្វាចដូចគ្នាទាំងអស់ ។

វណ្ណៈ    ចឹងហើយបានជាប្រជាជនអត់មានអីហូប?

ឈៀវៈ  បាទ!អត់មានអីហូប ។

វណ្ណៈ    ចឹងអ៊ំនៅខាងការពារហ្នឹងតាំងពីឆ្នាំ៧៥ដល់៧៩ហ្នឹងប្តូរមួយយ៉ាងម៉េច?

ឈៀវៈ  មានការផ្លាស់ប្តូរ  ជួនកាលដកយើងទៅនេះជួនកាលដកយើងទៅនោះទៅចល័តរហូតណាស់ ។

វណ្ណៈ    បាទ ។

ឈៀវៈ  ជួនកាលដកយើងឲ្យទៅខាងវៃចឹងទៅ  កាលខ្ញុំទៅដល់ច្រមុះជ្រូកនោះ ។

វណ្ណៈ    វៃជាមួយវៀតណាម?

ឈៀវៈ  បាទ!វៀតណាមហ្នឹង ។

វណ្ណៈ    ចឹងកាលហ្នឹងប្រធានកងពលដែលនាំទៅវៃជាមួយវៀតណាម?

ឈៀវៈ  កាលហ្នឹងគេដក  កាលហ្នឹងកងពលគេផ្លាស់ពីមួយទៅមួយរហូតតើ ។

វណ្ណៈ   បាទ ។

ឈៀវៈ  វាមាននៅជាប់រហូតណា ផ្លាស់ពីមួយទៅមួយ ។

វណ្ណៈ   ចឹងអត់មានចាំកន្លែងពេលបានទេពូ?

ឈៀវៈ  បាទ ។

វណ្ណៈ   ចឹងកាលពូទៅវៃជាមួយវៀតណាមពូទៅបានរយៈពេលប៉ុន្មានបានជាវៀតណាមវៃបុកចូលមកដល់ភ្នំពេញវិញ?

ឈៀវៈ  អត់មានបានវៃប៉ុន្មានអីប៉ុន្មានទេ ចុងឆ្នាំ៧៩ហ្នឹងវៀតណាមវាវៃបុកមកវិញ ។

វណ្ណៈ   ចឹងយើងរត់បណ្តោយ?

ឈៀវៈ  បាទ!យើងរត់ខ្ញុំផុងនៅស្រុកវៀតណាមហ្នឹងទៅ ។

វណ្ណៈ   ចឹងនៅវៀតណាម?

ឈៀវៈ  បាទ!នៅផុងទាល់តែវាមានកំលាំងច្រើនព័តហែលទឹកមកងាប់តាមមេគង្គមិនចេះតិចណាស់ ។

វណ្ណៈ   បាទ!ចឹងពូមានវៀតណាមចាប់បានទេ?

ឈៀវៈ  អត់ទេ អត់មានចាប់បានទេ មកដល់រហូតមកដល់ស្រុកភូមិឈប់បណ្តោយឈប់ចឹងទៅ ។

វណ្ណៈ   បាទ ។

ឈៀវៈ  ឈប់ចឹងទៅដល់ក្រោយគេមកព្រៃទៀត ឈប់ប្រហែលជាបានមួយខែតាមមើល ពួកហ្នឹងមកពីព្រៃ គេថាព្រៃយើងស្រួលបួលហើយ កាលហ្នឹងវៀតណាមមកដល់ចាប់យើងអ្នកណាមាននិន្នាការគេទៅប្រមាន ។

វណ្ណៈ   គេយកទៅអប់រំ?

ឈៀវៈ  បាទ!អប់រំដល់យើងខ្លាចក៏មកនៅនេះមករហូតមកទាល់រាល់ថ្ងៃនេះ ដោយសាចឹងឯង ។

វណ្ណៈ   ចឹងយើងបានចូលភូមិហើយតែយើងខ្លាចវៀតណាមចុចឈ្មោះយកទៅអប់រំយើងខ្លាចរត់ទៀតទៅ?

ឈៀវៈ  បាទ!យើងខ្លាចរត់ចឹងមកព្រៃដដែល១ហើយមកដាច់បាយដាច់ទឹកមានតែបួនដបម្តៃថ្ងៃនោះងាប់យើងណាស់ ខ្មែរយើងនៅតាមព្រំដែននេះងាប់ដោយសារថាអត់បាយហ្នឹងហើយ អូនឯងកើតទាន់សម័យក្រោយនេះទាន់គេសម្បូរសប្បាយណាស់ ។

វណ្ណៈ   បាទ ។

ឈៀវៈ  អឺនោះឆ្លងកាត់អស់ហើយបន្តិចទៅវាចប់បានហើយ ។

វណ្ណៈ ចឹងខ្ញុំចង់សួរក្នុងសម័យខ្មែរក្រហមហ្នឹងខាងកងទ័ពអត់មានការខុះខាតទេ អ៊ំ?

ឈៀវៈ វាថាខុះខាតក៏ដូចខុះខាតដែលអូន ធម្មតាយើងនៅសមរភូមិមានដាច់បាយដាច់អីញឹកញាប់ដែលហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ឈៀវៈ យើងហូបជាមួយបាយពូតហ្នឹងបាយបោក ។

វណ្ណៈ បាទ ។

ឈៀវៈ មានដាច់ដែលមានបានហូបដូចយើងរាល់ថ្ងៃសម្បូរសប្បាយចឹងទេ រាល់ថ្ងៃយើងខំប្រឹងរកសម្រាប់ជីវិតរបស់យើងអាចគ្រប់គ្រាន់ខ្វះវាខុះបន្តិចបន្តួចចឹងទៅ ។

វណ្ណៈ ចឹងរយៈពេលបីឆ្នាំហ្នឹងនៅកន្លែងរបស់អ៊ំហ្នឹងមានទាហានគេចាប់យកទៅណាបាត់ឬក៏មានប្រធានអីគេចាប់ដែរ?

ឈៀវៈ មានចាប់មេ ទាហានដូចអ៊ំអីអត់សូវភ័យទេ ឲ្យតែត្រឹមកេក្រុមឡើងទៅបាត់ខ្លួនគេថាបញ្ជូនទៅនេះបញ្ជូនទៅនោះ ផ្លាស់ទៅនេះផ្លាស់ទៅនោះតែការពិតមួយយប់ហើយមួយប់ហើយដែរ យើងមិនដឹងជាថាម៉េចចឹងណាស់ មនុស្សរស់នៅក្នុងសង្គមបើយើងមិនធ្វើតាមបែបបទគេក៏យើងពិបាកដែលហ្នឹងណាស់ ។

វណ្ណៈ បាទ!អ៊ំមានឆ្ងល់ទេថា យើងបានស្មោះនិងអង្គការដាក់ចិត្តដាក់កាយវៃឈ្នះទាហានលន់ នល់ហើយសុទ្ធតែខំតស៊ូអស់ពីចិត្តពីថ្លើមមិនគិតពីផលប្រយោជន៍ខ្លួនឯងមិនគិតពីឪពុកម្ដាយ មិនគិតពីបងប្អូនអីទាំងអស់ហើយទីបញ្ចប់ខ្មែរក្រហមយកអ្នកខំតស៊ូទៅសម្លាប់អ៊ំមានឆ្ងល់ទេ ថាហេតុអី អ៊ំគិតឃើញយ៉ាងម៉េចដែលត្រង់ចំណុចហ្នឹង?

ឈៀវៈ ដូចជាគិតមិនសូវឃើញទេ អូនព្រោះអ៊ំជាមនុស្សល្ងង់ណាស់ យើងមិនអាចស្រាវជ្រាវទៅចឹងដឹងទេ តែកាលដែលនិយាយនេះ និយាយតាមការពិតតែប៉ុណ្ណឹងទេណាស់ ។

វណ្ណៈ បាទ ។

ឈៀវៈ ហើយបើគំនិតគេនោះគេចង់ទៅជាស្អីៗទៀតក៏យើងអត់ដឹងដែរ ។

វណ្ណៈ បាទ ។

ឈៀវៈ ហើយយើងបំណងអីសានោះយើងមានបំណងធ្វើម៉េចឲ្យតែមានសេចក្ដីសុខ ទោះបីឆ្អែតមិនឆ្អែតឲ្យតែបានសេចក្ដីសុខកុំឲ្យតែស្លាប់ទៅបានហើយ ។

វណ្ណៈ បាទ ។

ឈៀវៈ ក្នុងគំនិតណាស់ ។

វណ្ណៈ ចឹងកាលហ្នឹងអ៊ំភ័យដែរ?

ឈៀវៈ ភ័យដូចតែគ្នាហ្នឹង តែយើងជាកូនទាហានបានខំតែធ្វើល្អហ្នឹងគេ តែគេអត់មានចាប់កូនទេគេចាប់តែមេៗចឹង ។

វណ្ណៈ ចឹងអ៊ំកាលហ្នឹងមានដឹងថា ប្រជាជននៅតាមសហករណ៍អត់បាយនិងសម្លាប់អ៊ំមានបានដឹងទេកាលហ្នឹង?

ឈៀវៈ ដឹងទាំងអស់ តែយើងមានអង្គការដូចរាល់ថ្ងៃយើងប្តឹងនេះប្តឹងនោះបាន ។

វណ្ណៈ បាទ ។

ឈៀវៈ ពីដើមអង្គការតែគេរហូតហើយមានអី កាលហ្នឹងខ្ញុំពាក្យថាអង្គការខ្ញុំស្រេវៗដែលហ្នឹង ។

វណ្ណៈ ព្រោះអង្គការពីមុនអត់ល្អ?

ឈៀវៈ បាទ!ពុថាអង្គការថ្នាក់លើហើយបែបភ័យដែលហ្នឹងណាស់ ។

វណ្ណៈ តែអង្គការសម័យឥឡូវអត់មានអីទេ មានអង្គការជាច្រើនបានជួយជ្រំជ្រែកជួយបណ្តុះបណ្តាលបង្កបង្កើនផលជួយបណ្តុះបណ្តាលអីចឹង?

ឈៀវៈ បាទ ។

វណ្ណៈ តែដូចអ៊ំនិយាយចឹង ឲ្យតែពុឈ្មោះអង្គការហើយគេសម្លាប់ណាយើងមិនអាចទៅប្តឹងផ្តល់គេអត់បានហើយមនុស្សដែលចាប់ទៅហ្នឹង ខ្លះមិនដឹងថាគេចាប់ដោយសារអីផង ហើយអត់មានតុលាការអត់មានអី ចឹងមានពីណាគេជួយរកខុសត្រូវឲ្យ ដឹងថាស្លាប់ៗចឹងហើយដូចថា អ៊ំគិតថាអាហ្នឹងជាកំហុសរបស់អ្នកដឹកនាំកំពូលដែលមែនទេឬយ៉ាងម៉េច?

ឈៀវៈ បាទ!គាត់ដឹកនាំកំពូលហើយចឹងទៅបើសិនគាត់មិនឲ្យសម្លាប់មនុស្សគ្មានពីណាហ៊ានសម្លាប់ដែរបើយើងគិតទៅ ។

វណ្ណៈ ចឹងអ៊ំជឿថាចឹង?

ឈៀវៈ បាទ!ខ្ញុំជឿថាចឹងដែរ ។

វណ្ណៈ បាទ ។

ឈៀវៈ បើអ្នកឲ្យដៃគឺឲ្យពីលើហ្នឹងឯង ដូចជាសម្តេចហ៊ុន សែនរាល់ថ្ងៃបើគាត់ឲ្យដៃគឺឲ្យពីលើហ្នឹងឯងហើយ ។

វណ្ណៈ បាទ ។

ឈឿវៈ បើសិនជាលួចលាក់ បើគាត់មិនធ្វើពួកហ្នឹងហ៊ានធ្វើអាហ្នឹងរឿងតែម្តង បើគាត់ឲ្យធ្វើអាហ្នឹង អាចស្ងប់ស្ងាត់ណាស់ ។

វណ្ណៈ បាទ ។

ឈឿវៈ អាហ្នឹងគំនិតខ្ញុំដឹងត្រឹមណឹង ។

វណ្ណៈ ចឹងដូចជាតា ខៀវ សំផលគាត់ប្រកែកថាគាត់មិនបានដឹងទេ រឿងរ៉ាវទាំងអស់ហ្នឹងរឿងកាប់សម្លាប់អីចឹងអ៊ំជឿបានទេ?

ឈឿវៈ ទេ អារឿងជឿមិនជឿអាហ្នឹងរឿងតុលាការដែលសួរបញ្ជាក់គាត់ ខ្ញុំអត់មានទៅបញ្ហាអីទេ ព្រោះខ្ញុំយ៉ាប់ដែរ ។

វណ្ណៈ បាទ ។

ឈឿវៈ រស់នៅក្នុងសង្គមគេមួយហ្នឹងគេដែលក៏ប៉ុន្តែយ៉ាប់ ។

វណ្ណៈ បាទ ។

ឈឿវៈ រាល់ថ្ងៃគេអត់សួរជឿរឿងចំណោមខាងហ្នឹងទេ ប្រជាជនយើងសរុបប៉ុន្មានសែនជិតបីលាននោះ ។

វណ្ណៈ តែខាងអង្គការរកឃើញជាងមួយលាន ។

ឈឿវៈ តែដល់ចឹងបានថា បើតាមចិត្តខ្ញុំវិញថា០០១ ០០២ ០០៣និង០០៤ឲ្យរកឲ្យអស់រកឲ្យឃើញតែម្តង ។

វណ្ណៈ ចឹង?

ឈឿវៈ បាទ!បានត្រឹមត្រូវ ។

វណ្ណៈ ចឹងអ៊ំចង់ឲ្យរក០៣ និង០៤ទៀត?

ឈឿវៈ បាទ!ឲ្យរកទាំងអស់បានត្រឹមត្រូវតែម្តង ។

វណ្ណៈ ចឹងបើមានត្រឹម០១និង០២អ៊ំថាមានយុត្តិធម៌គ្រប់គ្រាន់ទេ?

ឈឿវៈ អត់ទាន់គ្រប់គ្រាន់ទេ ព្រោះវាមានច្បាប់ដល់ខាងលើចឹងទៅមកចុចចំណុចចឹងទៅស្រាវជ្រាវយកទៅទាំងអស់តែម្តង ។

វណ្ណៈ បាទ ។

ឈឿវៈ អ្នកណាទោសប៉ុន្មានៗក៏ឲ្យទៅវាបានក្លាក់រលីកដែរ ។

វណ្ណៈ បាទ ។

ឈៀវៈ ខ្ញុំចង់ចឹងដែលណាស់ ។

វណ្ណៈ ចឹងអ៊ឹមានតាមដានតុលាការតាមដានអីដែរទេ?

ឈៀវៈ បាទ!តាមដានស្តាប់វិទ្យុរហូតដែលតើ ចេះតែចង់ស្តាប់ចង់មើលត្បិតនៅតែក្នុងព្រៃមែនតែចង់ដឹងឲ្យវាឃើញសខ្មៅ ។

វណ្ណៈ ចឹងចង់ដឹងឲ្យឃើញសខ្មៅដែរ?

ឈៀវៈ បាទ!ចង់ដឹងថាហេតុអីបានទៅជាចឹង ដលមាន០១និង០២ចប់ចឹងអត់ដឹងណាណីវាអត់ដឹងថាចប់សាច់រឿង ។

វណ្ណៈ ចឹងអ៊ឹគិតថា សង្គ្រាមសម្លាប់ខ្មែរគ្នាឯងកន្លងមកចឹង អ៊ឹគិតថាមកពីអ្នកនយោបាយយើងឬមួយមកពីខាងណាឬមានគេញួសញ៉ុងយើងបើតាមអ៊ឹយល់?

ឈៀវៈ មិនអាចដឹងបានទេអូន ព្រោះយើងថាពីណាញួសញ៉ុងក៏ដោយបើយើងជាមេដឹកនាំដល់កំពូលហើយបើស្តាប់គេដឹងថាខុសខ្ញុំដឹងតែប៉ុណ្ណឹង ។

វណ្ណៈ បាទ ។

ឈៀវៈ បើសិនជាគេញួសញ៉ុងអីលិចកើត ហេតុបានគេជួយ ។

វណ្ណៈ បើអ៊ឹបានមើលឯកសារទៀតគួរឲ្យស្រណោះ ខ្ញុំជាក្មេងជំនាន់ក្រោយខ្ញុំបានមើលឯកសារស្រណោះមែនទែនក្មេងៗប៉ុនៗណឹងកាន់កាំភ្លើងដែរ ហើយទាហានលន់ នល់ចាប់បានទាហានខ្មែរក្រហមក៏សម្លាប់ចោលហើយខាងខ្មែរក្រហមចាប់បានទាហានលន់ នល់ក៏សម្លាប់ចោលដូចតែគ្នាហើយការដែលបាញ់គ្នាហ្នឹងស្លាប់គរដូចអុសចឹង មើលក្នុងកាសែតបារាំងថតបាននោះឃើញសាហាវណាស់ ចឹងខ្មែរស្លាប់ហើយសង្គ្រាមយើងរាប់សិបឆ្នាំមកហើយ ហើយយើងមើលថ្ងៃវាជឿនលឿនដោយសារវាអត់មានសង្គ្រាមជិត១០០ឆ្នាំហើយ ។

ឈៀវៈ បាទ ។

វណ្ណៈ ឥឡូវយើងស្ងប់ហើយរៀងខ្មែរនិងខ្មែរជាមួយបរទេសយើងនៅពាក់ព័ន្ធខ្លះដែលអ៊ឹណាស់ ។

ឈៀវៈ បាទ ។

វណ្ណៈ វាមិនទាន់បានស្រួលមែនទែនទេ ។

ឈៀវៈ នេះបានថាចង់សួរពីណាទៅណីឲ្យបរទេសមកជួយគាំទ្រយ៉ាងម៉េចៗឲ្យសម្លាប់ខ្មែរអស់រលីងចឹងគេចង់ដឹងប៉ុណ្ណឹងទៀត ។

វណ្ណៈ បាទ ។

ឈៀវៈ ចឹងមុនសាប់ទៅវិញឲ្យដឹងបានច្បាស់លាស់ដែរ ។

វណ្ណៈ ដោយសារប្រទេសយើងក៏ចូលជាមួយអង្គការសហប្រជាជាតិហើយតុលាការនេះក៏ជាតុលាការអន្តរជាតិដែរ?

ឈៀវៈ បាទ ។

វណ្ណៈ ចូលជាមួយខ្មែរយើងដើម្បីធ្វើការកាត់ទោសឲ្យដឹងសខ្មៅនេះ ។

ឈៀវៈ បាទ ។

វណ្ណៈ ប៉ុន្តែតុលាការមានការចំរូងចំរាស់ខ្លះដល់បច្ចុប្បន្ននេះ ដូចខាងព្រះរាជអាជ្ញាបរទេសហ្នឹងគេចង់កាត់០០៣និង០០៤ទៀត តែខាងរដ្ឋាភិបាលមិនចង់ឲ្យមានការរីករាលដាលទៀតខ្លះចេះខ្លាចចុះណាស់?

ឈៀវៈ បាទ ។

វណ្ណៈ តែបញ្ហាហ្នឹងស្រេចគេខាងតុលាការទេ?

ឈៀវៈ យើងស្រែទៅគេធ្វើមិនដឹងផង ។

វណ្ណៈ បាទ!តែយើងគ្រាន់តែពិភាក្សាចង់យល់ដឹងរបស់បងប្អូនតែប៉ុណ្ណឹង?

ឈៀវៈ បាទ ។

វណ្ណៈ ចឹងខ្ញុំចង់និយាយបកទៅក្រោយបន្តិច ពេលអ៊ំមកដល់ស្រុកហើយ៧៩ហ្នឹងអ៊ំរត់ចូលព្រៃវិញមែនទេ?

ឈៀវៈ បាទ ។

វណ្ណៈ កាលហ្នឹងអ៊ំចូលព្រៃចូលទៅខាងណាទៅ?

ឈៀវៈ មុនដំបូងទៅខាងភ្នំដងរែក ។

វណ្ណៈ ចឹងទៅដងរែកទៅខាងតា ម៉ុកចឹង?

ឈៀវៈ បាទ!ទៅខាងណាម៉ុក ។

វណ្ណៈ ចឹងនិយាយមើលក្រោយមកគេសម្លាប់០៦អីហ្នឹងអ៊ំមានបានដឹងរឿងហ្នឹងដែរ?

ឈៀវៈ ចូលទៅខាងនោះដល់ចឹងទៅបានគេខាងនេះប្រជាជនវាតិច ម្លោះហើយតា ម៉ុកបញ្ជូនមកនេះមកខាងកោះកុងយើងនេះណាស់ ។

វណ្ណៈ ចឹងមកហ្នឹងមកតាមតា សុន សេន?

ឈៀវៈ មកនេះមកតាមទន្លេសាបចេញមកដោយថ្មើជើង ។

វណ្ណៈ ចឹងអត់មាននៅជាមួយតា ម៉ុក រហូតទេ?

ឈឿវៈ បាទ!មិនបាននៅរហូតទេ ។

វណ្ណៈ អ៊ឹ នៅដល់ឆ្នាំណា នៅជាមួយតាម៉ុកដល់ឆ្នាំណា?

ឈឿវៈ នៅជាមួយតា ម៉ុកឆ្នាំ៨៧ ។

វណ្ណៈ ៨៧ណែស?

ឈឿវៈ បាទ ។

វណ្ណៈ ចឹងពី៧៩ដល់៨៧?

ឈឿវៈ បាទ ។

វណ្ណៈ កាលហ្នឹងមានអាវុធអីមានទេ?

ឈឿវៈ កាលហ្នឹងមានអាវុធគ្រប់គ្រាន់ ។

វណ្ណៈ តែអត់មានប្រាក់ខែទេ?

ឈឿវៈ អត់មានទេ ។

វណ្ណៈ កាលហ្នឹងមានដឹងថាយួនស្លាប់ច្រើនដែរ?

ឈឿវៈ ស្លាប់ច្រើនណាស់ អើ បើសាចទឹកដាក់គ្នាវាចេះតែមានទៅវិញទៅមក ។

វណ្ណៈ បាទ ។

ឈឿវៈ ខាងគេស្គាល់ខាងគេខាងយើងស្គាល់ខាងយើងចឹងទៅ ។

វណ្ណៈ អ៊ឹកាលហ្នឹងប្រធានកងពលតា ០៦មែនទេ?

ឈឿវៈ កងពលដែលមកនៅនេះ ។

វណ្ណៈ ខ្ញុំចង់និយាយថា កាលនៅអន្លង់វែង?

ឈឿវៈ នៅអន្លង់វែងតានេះ... ។

វណ្ណៈ តា សារឿន?

ឈឿវៈ អត់តា សារឿនទេ តាប៉ាវ ។

វណ្ណៈ ចឹងមានឈ្មោះតា ប៉ាវទៀត?

ឈឿវៈ បាទ!តា ប៉ាវ ។

វណ្ណៈ តា ប៉ាវមិនដែលឮឈ្មោះ?

ឈឿវៈ តា ប៉ាវ ។

វណ្ណៈ  នៅក្រោមបញ្ជារបស់តា ម៉ុកហ្នឹង?

ឈឿវៈ ក្រោមបញ្ជាទាំងអស់ ។

វណ្ណៈ  តា ម៉ុកនៅនោះធំជាងគេ?

ឈឿវៈ ធំជាងគេ ។

វណ្ណៈ  ចឹងក្រោយមកទៀត?

ឈឿវៈ ក្រោយមកទៀតខ្ញុំមកនេះមកជាមួយតា ប៉ា តា ប៉ាយើងហ្នឹងណាស់ តា ប៉ា តា ស៊ូ តា ស៊ូថា ជួញគ្រឿងញានគេដាក់គុកដាក់ច្រវ៉ាក់ហ្នឹង ។

វណ្ណៈ  តា ស៊ូប្រធានកងពល?

ឈឿវៈ បាទៗ!ប្រធានកងពល ។

វណ្ណៈ  ចឹងនៅហ្នឹងមានតា ប៉ា?

ឈឿវៈ តា ប៉ាយើងបានបំបែកមកបានមានកងពលថ្មីបានចូលមកបាននៅតា គង់ តា ជាតិមកនៅតែដល់យើងចេញមកនេះមកខ្ញុំចេញមកនេះមក ។

វណ្ណៈ  តា គង់ តា សុខ គង់អភិបាលខេត្តហ្នឹង?

ឈឿវៈ បាទ ។

វណ្ណៈ  អភិបាលខេត្តបាត់ដំបង?

ឈឿវៈ អត់អភិបាលទេ កងពល ។

វណ្ណៈ  ពីមុនគាត់កងពល?

ឈឿវៈ រងតា ជឹយ ។

វណ្ណៈ  ឥឡូវគាត់អភិបាលរងខេត្តបាត់ដំបង?

ឈឿវៈ ចឹង ។

វណ្ណៈ  សុខ គង់ហ្នឹងមែនទេ?

ឈឿវៈ ញ៉ែម គង់ ។

វណ្ណៈ  ញ៉ែមទេ គង់ទេ?

ឈឿវៈ បាទ!ញ៉ែម គង់ ។

វណ្ណៈ  ញ៉ែម គងប្រធានកងពលដែរ?

ឈឿវៈ បាទ!ប្រធានកងពល ។

វណ្ណៈ	ចឹងគាត់នៅកាន់ខាងពោធិសាត់នេះ?

ឈឿវៈ	ទេ ខាងសំឡូតខាងបាត់ដំបងដែលពីមុនណាស់ ដល់ខ្ញុំចេញមកនេះមកបានមកនៅជាមួយវរៈកងពល៧១គា ពៅ បានរំលាយចូលទៅខាងនោះទៀតតាស្ពី..កងពល១៨គា ស្ពីទេ តាថោង ប្រាសាទបានចប់រាល់ថ្ងៃហ្នឹង ។

វណ្ណៈ	ចឹងពួកគាត់ទាំងអស់ហ្នឹងសុទ្ធតែនៅរស់ទេ?

ឈឿវៈ	រស់ ថោង ប្រាសាទនៅរាល់ថ្ងៃ ។

វណ្ណៈ	ចឹងអឹថា៧៩-៨៧នៅដងរែក?

ឈឿវៈ	បាទ ។

វណ្ណៈ	ចឹង៨៧ចេញពីដងរែកមកនៅសំឡូតទៀត?

ឈឿវៈ	បាទ!មកនៅសំឡូត ។

វណ្ណៈ	ចឹងមកនៅសំឡូតមានស្គាល់មាសមុតអីទេ?

ឈឿវៈ	មាស មុត ស្គាល់តើ ។

វណ្ណៈ	ហ្នឹងហើយគាត់ជាប្រធានកងពលនៅនេះ?

ឈឿវៈ	បាទ! តែគាត់លើសគេបំផុតហើយណាស់ ឋានៈគាត់តម្លើងកងពលបាន ។

វណ្ណៈ	បាទ!ចឹងក្រោមមកមានតា ម៉េតអីទៀត?

ឈឿវៈ	បាទ! តា ម៉េត តា មុតហ្នឹងគាត់អាចតម្លើងកងពលក្រោមបន្ទាប់គាត់បានណាស់ ។

វណ្ណៈ	ចឹងចេញពីសំឡូត?

ឈឿវៈ	ចេញពីសំឡូតទៅចូលជំរុំ យើងរត់ចូលជំរុំថៃដូចជាចង់ភ្លេចហើយយូរ ។

វណ្ណៈ	ជំរុំ៨៥អី?

ឈឿវៈ	ចូល៩០ហើយ ៩០ជាងហើយយើងចូលជំរុំខេត្តភ្នូនោះ ។

វណ្ណៈ	ចឹងចេញពីជំរុំមកហ្នឹង?

ឈឿវៈ	បាទ!ចេញពីជំរុំមកនេះបណ្តោយ ។

វណ្ណៈ	ចឹងមកនេះគេហៅវាលវែងហ្នឹងតែម្តង?

ឈឿវៈ	បាទ!គេហៅវាលវែង ។

វណ្ណៈ	ចឹងអឹចេញពីជំរុំមកនៅវាលវែងនេះឆ្នាំណា?

ឈឿវៈ	ឆ្នាំ៩៩ ។

វណ្ណៈ ៩៩សមាហរណ៍កម្មហើយអស់ហើយហ្នឹង?

ឈៀវៈ បាទ!សមាហរណ៍កម្មដែលយើងចេញមកហ្នឹង ។

វណ្ណៈ បាទ ។

ឈៀវៈ យើងចេញមកនៅនេះតែម្ដង ។

វណ្ណៈ ចឹងនៅខាងវាលវែងហ្នឹងប្រធានកងពលជាពីណា?

ឈៀវៈ នៅវាលវែងហ្នឹងមានតា ពៅហ្នឹងកងពល៧១ ។

វណ្ណៈ ប្រធានកងពលតែម្ដងហ្នឹង?

ឈៀវៈ បាទ ។

វណ្ណៈ គាត់ឈ្មោះ អីពៅទៅ?

ឈៀវៈ ទេ មិនដឹងដែលមិនដឹងថាឈ្មោះអីពៅទេ ។

វណ្ណៈ តែមួយហ្នឹងឬមានពីណាទៀត?

ឈៀវៈ អត់មានទេ មានតែមួយ ។

វណ្ណៈ ចឹងតា ពៅជាប្រធានកងពលនៅវាលវែង?

ឈៀវៈ បាទ ។

វណ្ណៈ ឥឡូវគាត់នៅរស់ដែលទេ?

ឈៀវៈ គាត់នៅរស់ គាត់ឈ្មោះអី គឹម ពៅចឹងហើយ ។

វណ្ណៈ គឹម ពៅ?

ឈៀវៈ បាទ!គឹម ពៅ ចឹងបានថាគាត់បំបែកគាត់នៅក្រោមតា ថោង ប្រាសាទវិញឥឡូវ ថោង ប្រាសាទគាត់ប្រធានកងពល១៨ ។

វណ្ណៈ បាទ!ចឹងអឹមកដល់៩៩ហ្នឹងនៅមានព្រៃមានសត្វមានអីច្រើនទេ?

ឈៀវៈ អូស!សុទ្ធតែព្រៃមកតាមនេះគ្មានដើមអីចេះទេ តាមថ្នល់ហ្នឹងក៏សុទ្ធតែព្រៃដែលសុទ្ធតែព្រៃ សុទ្ធតែមីន ។

វណ្ណៈ ចឹងមានមីនច្រើនដូចនៅសំឡូតភ្នំព្រឹកអីទេ?

ឈៀវៈ ដូចគ្នានេះផ្លូវ៥៦នេះសុទ្ធតែមីនហើយ ។

វណ្ណៈ ចឹងផ្លូវហ្នឹងផ្លូវ៥៦?

ឈៀវៈ បាទ ។

វណ្ណៈ	និយាយទៅសង្គ្រាមមួយរយៈចុងក្រោយមកទៀតហ្នឹងអ្នកពិការដោយសាសង្គ្រាមក៏ច្រើន ដោយសាកាប់ព្រៃក៏មានគ្រោះថ្នាក់បន្តបន្ទាប់ទៀតអី?

ឈឿវៈ	បាទ!រាល់ថ្ងៃហ្នឹងបានស៊ីម៉ាក់ដោះទៅបានវាសម្រាលណាស់ ។

វណ្ណៈ	ចឹងនិយាយត្រឡប់ទៅក្រោយបន្តិចវិញ យើងនិយាយសម័យតស៊ូនិងសម័យឥឡូវនេះអ៊ីគិតថាពីមុនមកដល់ឥឡូវមានការអភិវឌ្ឍន៍យ៉ាងម៉េច ឬក៏វាមិនមានការអភិវឌ្ឍន៍ទេ ពីមុនអាចស្រួលជាងសម័យឥឡូវឬមួយយ៉ាងម៉េចអី?

ឈឿវៈ	អត់ទេ គឺសម័យឥឡូវវាស្រួលជាង បានថាមុនយើងមិនបានទេ ដេកក៏មិនស្រួលរាល់ថ្ងៃយើងបានពួកខ្មែរតាមសេរីយើងចង់ធ្វើអីធ្វើទៅ យើងចង់ដេកៗ ។

វណ្ណៈ	បាទ ។

ឈឿវៈ	យើងបានប៉ុណ្ណឹងដែលណាស់ ។

វណ្ណៈ	បាទ ។

ឈឿវៈ	តែយើងនៅតែក្រ ព្រោះយើងមិនទាន់ម្ចាស់ការខ្លួនឯងបានទាំងស្រុងណាស់ ។

វណ្ណៈ	បាទ ។

ឈឿវៈ	វានៅតែក្រទេ តែយើងធ្វើម៉េចតាមវាសនារបស់យើងទៅចុះឲ្យវាបានប៉ុណ្ណឹងក៏បានដែរ ។

វណ្ណៈ	បាទ ។

ឈឿវៈ	បានដេកលក់ស្រួលស៊ីឆ្ងាញ់ចឹងទៅ ថ្ងៃណាឆ្ងាញ់ខ្លះចឹងទៅថ្ងៃណាក៏អត់ខ្លះចឹងទៅក៏តាមធម្មតារបស់មនុស្សយើង ។

វណ្ណៈ	បាទ ។

ឈឿវៈ	តាមក្រតាមមានណាស់ ។

វណ្ណៈ	បាទ!ចឹងពីមុនមកយើងហូបដោយមិនបាច់ភ័យរឿងរកមែន ប៉ុន្តែយើងមិនបានស្នាក់នៅមានផ្ទះធំដុំស្រួលបួលទេ ដោយសារសង្គ្រាមអីណែស?

ឈឿវៈ	បាទ!មានតែអង្រឹងមួយជួលកាលគេវៃផ្លូងដាំងបាត់អង្រឹងអស់រលីងដេកនិងដីក៏មានដែរ ។

វណ្ណៈ	យើងរត់កាត់គ្រាប់កាត់ភ្លៀង?

ឈឿវៈ	បាទ!រាល់ថ្ងៃវាស្រួលដែរ យើងរកនេះរកនោះយើងបានទប់ទល់ជីវភាពក្នុងគ្រួសារ ។

វណ្ណៈ	បាទ ។

ឈឿវៈ	យើងចង់ធ្វើធ្វើទៅ យើងមិនចង់ធ្វើយើងដេកទៅ ចង់ដើរៗចង់ដេកៗទៅ ។

វណ្ណៈ បាទ!តែខាងភ្នំព្រឹកអីបងប្អូនអតីតរស់នៅហ្នឹងឃើញគេមានជីវភាពធូរធារជាងខាងនេះ ។
ឈៀវៈ បាទ ។
វណ្ណៈ ខ្ញុំតាមមើលទៅគេត្រូវប៉ុន់ដំឡូងឆ្នាំទៅ ។
ឈៀវៈ បាទ ។
វណ្ណៈ នៅខាងនេះដូចជាអត់ទាន់ឃើញមានដាំដំឡូង?
ឈៀវៈ ឥឡូវមានគេយកដាំហើយ គេទើបយកដើមមក ។
វណ្ណៈ បាទ!ចឹងនៅនេះបន្តិចទៀតខ្ញុំថាស្រួលដែលនៅទីនេះឃើញមានភ្លើងអីចឹងបន្តិចទៀតប្រហែល
ជាមានផ្លូវអីហើយ ។
ឈៀវៈ បាទ ។
វណ្ណៈ សំខាន់ភ្លើង នៅខាងភ្នំព្រឹកនោះគេបានភ្លើងមកពីថៃចឹងទៅគេចង់ធ្វើអីចឹងវាបានស្រួលអីចឹង ។
ឈៀវៈ ខាងភ្នំរពឹកនិងគេរកស៊ីមុនយើងនេះទៀត ។
វណ្ណៈ បាទ ។
ឈៀវៈ ខាងនោះគេបើកឲ្យរកស៊ីមុនយើង ព្រោះខាងសំឡូតខាងអី ។
វណ្ណៈ ចឹងយើងបន្តិចទៀតទៅក៏បានស្រួលដែលតាមមើល ។
ឈៀវៈ បាទ ។
វណ្ណៈ ចឹងអ៊ីខ្ញុំអរគុណអ៊ំច្រើនហើយ ។
ឈៀវៈ បាទ ។
វណ្ណៈ អ៊ំបានផ្ដល់បទសម្ភាសន៍ឲ្យខាងខ្ញុំអ៊ំ ។
ឈៀវៈ បាទ!អរគុណហើយណាស់ ។
វណ្ណៈ បាទៗ ៗ ។
ឈៀវៈ ខ្ញុំទៅផ្ទះខ្ញុំវិញហើយណាស់ ។
វណ្ណៈ បាទ!អរគុណអ៊ំ ។

**ចប់**